D119585 DC-Cam

# របាយការណ៍
# ស្តីអំពីសកម្មភាពលទ្ធផលការងារ
# ស្រាវជ្រាវទីតាំងប្រល័យពូជសាសន៍
# នៅខេត្តកំពង់ស្ពឺ

នៅថ្ងៃទី ៨ ខែមិថុនា ក្រុមមជ្ឈមណ្ឌលស្រាវជ្រាវឯកសារទាក់ទងទីតាំងប្រល័យពូជសាសន៍ពួកខ្មែរក្រហមមានគ្នា ៣នាក់ ដឹកនាំដោយលោក **ស៊ិន ឃិន** និងលោក **ផាត កុសល** ហើយនិង លោក ..................... ជាសហការី ។

## ខេត្តកំពង់ស្ពឺ

ក្រុមយើងបានធ្វើដំណើរពីរាជធានីភ្នំពេញ តាមបណ្តោយផ្លូវជាតិលេខ៤ ទៅដល់សាលាខេត្ត ម៉ោង ៩ព្រឹក នៅទីនោះយើងបានជួបឯកឧត្តម **យឹម សុខុម** អភិបាលខេត្តរងទី៣ ដើម្បីសំរួលការងារ ចៅហ្វាយខេត្តបានចេញលិខិតខ្ទេសនាម អនុញ្ញាតិឲ្យយើងចុះទៅគ្រប់មន្ទីរពាក់ពន្ធ័និងបណ្តាស្រុកទូទាំង ខេត្ត ។ តមកទៀត យើងទៅជួបលោកវរសេនីយឯក **មៀច មឿន** អធិការដ្ឋាននគរបាលខេត្តកំពង់ស្ពឺ គាត់បានចេញខ្ទេសនាមអោយយើងទៅទាក់ទងស្នងការនគរបាលទូទាំងស្រុក ចំណុះខេត្តកំពង់ស្ពឺ ។

## លក្ខណៈភូមិសាស្រ្ត

ខេត្តកំពង់ស្ពឺ ជាតំបន់ខ្ពង់រាប សំបូរណ៍ទៅដោយព្រៃភ្នំខ្ពស់ និងធំវែងៗ ឋិតនៅតាមដងផ្លូវជាតិ លេខ៤ ពីភ្នំពេញទៅទីក្រុងព្រះសីហនុ ចំងាយ ៤៨គីឡូម៉ែត្រ ពីទីក្រុងភ្នំពេញ ។ សម័យ **ប៉ុល ពត** ទិសនីរតី តំបន់ ៣៣ ខាងត្បូងថ្នល់ តំបន់ ៣២ ខាងជើងថ្នល់ ។

ចំនួនប្រជាជនបច្ចុប្បន្ន ឆ្នាំ ១៩៧៩ មុនឆ្នាំ ១៩៧០ យើងក្តាប់មិនបាន ព្រោះពេលវេលាខ្លី មិនអាចទារយករបាយការណ៍បាន ។

## I- ស្រុកភ្នំស្រួច

ក្រុមយើងបានចេញដំណើរពីខេត្តកំពង់ស្ពឺ តាមដងផ្លូវជាតិលេខ ៤ ឆ្ពោះទៅកាន់ស្រុកភ្នំស្រួច ម៉ោង ១០:០០ ដល់សាលាស្រុក យើងបានជួបលោកប្រធានមន្ទីរសាលាស្រុកឈ្មោះ **ឆួន ឆន** និង

លោកអភិបាលស្រុក **សត្យា ទុច** និងស្នងការនគរបាលស្រុក ។ បំណងជួបវប្បធម៌ស្រុក ប៉ុន្តែមិន បានជួប ព្រោះគេជាប់ជាគណៈកម្មការរៀបចំការបោះឆ្នោតអស់ហើយ ។

## <u>អំពីពត៌មានផ្សេងៗ</u>

ចៅហ្វាយស្រុកបានរាយការណ៍ អោយយើងដឹងអំពី ៈ

\+ **<u>លក្ខណៈភូមិសាស្ត្រ</u>**

ទីតាំងស្រុកឋិតនៅជាប់ផ្លូវជាតិលេខ ៤ ចំងាយពីសាលាខេត្ត ២០គីឡូម៉ែត្រ ខាងឆ្វេងដៃ ស្រុកនេះជាតំបន់ខ្ពង់រាប សំបូរណ៍ទៅដោយព្រៃ និងភ្នំធំៗ ដែលជាប់ៗគ្នា ។ មានឃុំ ១២ ចំណុះ ៩ភូមិ ។

- ព្រំប្រទល់ទីតាំងស្រុក

- ខាងលិច ស្រុកស្រែអំបិល កោះកុង
- ខាងកើត ទីរួមខេត្ត ស្រុកច្បារមន
- ខាងជើង ស្រុកឱរ៉ាល់
- ខាងត្បូង ស្រុកបសេដ្ឋ

ចំនួនប្រជាជនបច្ចុប្បន្ន ឆ្នាំ ១៩៧៩ មុនឆ្នាំ១៩៧០ យើងគ្មានរបាយការណ៍ ដោយម៉ោង ១០ព្រឹកទៅហើយ ស្រង់មិនទាន់ ។ (អាចលើកក្រោយៗទៀត) ។

ចំនួនឃុំ ដែលមានទីតាំងប្រល័យពូជសាសន៍ ដែលលោកចៅហ្វាយស្រុកបានរាយការណ៍

១- <u>ឃុំអូរ</u> ៈ

ក- ទួលដា

ខ- ក្រាំងសំរ៉ែ

គ- PA1-PA2-PA3 (ជាទីតាំងពួកទាហ៊ាន **លន់ ណុល** សម័យសាធារណៈរដ្ឋ)

២- <u>ឃុំដំបូករូងខ្ពស់</u>

ក- ដុកអិល

ខ- តុងឡុង

៣- <u>ឃុំព្រៃក្មេង</u>

៤- <u>ឃុំតាំងស្យា</u>

ក- ភ្នំក្រលាក់

ខ- កប់ឆ្កែ

គ- ភ្នំឃ្លោស

+ **បញ្ហាសន្តិសុខ**

ខាងត្បូងថ្នល់ជាតិ តំបន់ឆ្ងាយៗអស្ថេរភាព មិនអាចធានាបាន មានចោរព្រៃផ្គាប់ខ្លួន រត់ចូលព្រៃវិញផ្ញើចោរប្លន់ ចាប់ជំរិតយកប្រាក់ពីប្រជាជន ថៅកែធំៗ ជនបរទេស ឆ្នាំ ១៩៩៨ ខែ១ ខែ២ នេះ ខ្លាំងនៅឡើយ ។ ពេលយើងចុះវាបិទប្រកាសថានរណាហ៊ានចូលព្រៃភ្នំខាងត្បូងថ្នល់ វាវះពោះច្រកស្មៅ ។

**អំពីទីតាំងប្រល័យពូជសាសន៍**

នៅម៉ោង ១០:៣០នាទី យើងបានចេញដំណើរពីសាលាស្រុកទៅស្រាវជ្រាវទីតាំងតាមពត៌មាន ដែលចៅហ្វាយស្រុកបានប្រាប់យើង យើងទៅឃុំអូរ ជួបមេឃុំ មេឃុំបានប្រាប់យើង ពេលទៅជួបលោក **ខៀវ មឿន** មន្ត្រីអប់រំវប្បធម៌ឃុំអូរ យើងបានរួមដំណើរនិងប៉ូលិសស្រុក ២នាក់ ចុះទៅផ្លូវខាងត្បូង ថ្នល់មានចំងាយ ១០០ម៉ែត្រ ដល់ផ្ទះគាត់ **ខៀវ មឿន** គាត់បានប្រាប់យើងនូវទីតាំងក្នុងឃុំអូរទាំងអស់ដែលគាត់ដឹង

+ **ទីតាំងប្រល័យពូជសាសន៍ វត្តពុទ្រា**

**PA 1 - PA 2 - PA 3**

ក្រុមយើងបានចុះទៅរកទីតាំងនេះ ថយក្រោយ ១គីឡូម៉ែត្រ បត់ស្តាំតំរង់ទៅទីនោះ ចំងាយពីផ្លូវជាតិលេខ៤ ប្រហែល ១២០០ម៉ែត្រ បត់ឆ្វេងដៃ ដល់ទីតាំងវត្តពុទ្រា ។ នៅទីនោះយើងបានជួបមេបញ្ជាការប៉ូលីសប្រចាំការនៅវត្តនេះ យើងសួរបស្ទង់បញ្ហាសន្តិសុខ ក្រោយមកដឹងថាមិនអីទេ យើងស្វែងរកអ្នកដឹង ឃើញ ហើយធ្លាប់រស់នៅទីនោះតាំងពីមុនៗមក ។

**អំពីពតិមាន**

យើងបានជួបលោកតា **សាន់ ខៀវ** បច្ចុប្បន្នអនុប្រធានភូមិរលួស ឃុំអូរ ស្រុកភ្នំស្រួច ខេត្ត កំពង់ស្ពឺ ។ សម័យ **ប៉ុល ពត** មុខរបរឡើងត្នោត នៅភូមិ ឃុំ ស្រុក ខេត្តនេះតែម្តង ។

យើងបានសុំអោយគាត់ធ្វើសាក្សី ពីព្រោះគាត់បានដឹង ឃើញ ឮ ផ្ទាល់តែម្តង គាត់បានប្រាប់យើងថា នៅខាងកើតវត្តចំងាយពី ១,០០០ម៉ែត្រ ទៅ ១,២០០ ម៉ែត្រ មានទីតាំងកាប់សម្លាប់ ២កន្លែង គឺ PA1- និង PA2- និងខាងត្បូងវត្ត ឆៀងខាងលិចមាន ១កន្លែង ទៀត គឺ PA3- ។

<u>ពន្យល់ពាក្យ PA1- និង PA2- និង PA3-</u> នេះជាទីតាំងពួកទាហ៊ាន **លន់ ណុល** ជាប៉ុស្តិ៍ជួរមុខបន្ទាយ ពួកគេទប់ទំនប់ខ្ពស់ រាងជាត្រីកោណ មុំស្រួច ប្រយោជន៍ដាក់កាំភ្លើងធំ តូច និងលេណដ្ឋានស្នាក់នៅ ពួកទាហ៊ាន ឆ្នាំ ១៩៧០-៧៥ ។ ទំហំទីតាំងនីមួយៗ ពី ៥០ ទៅ ៦០ម៉ែត្រ បួនជ្រុង ។

ប្រភេទជនរងគ្រោះត្រូវសម្លាប់នៅទីនេះ

8 សាក្សីបានប្រាប់យើងថា ជនរងគ្រោះយកមកសម្លាប់ ៣ កន្លែងនេះ ជាទាហាន **លន់ ណុល** ចងបណ្តើរពីបន្ទាយដោះកញ្ជរ នៅឆ្នាំ ១៩៧០-៧៥ ។ ពួកឃាតករបណ្តើររាល់ថ្ងៃ ម៉ោង ៩ព្រឹក សម្លាប់ ម៉ោង ១០ ទៅ ១០ៈ៣០នាទី ដោយបាញ់រះនិងកាំភ្លើង សាក្សី **សាន់ ឡេង** គាត់មើលឃើញពីលើដើមត្នោត គាត់កំពុងដាក់ទឹកត្នោត ព្វសូរសម្រែក ស្រែក ជួយផង១ អួយ១ ។

8 ចំនួនរណ្តៅ ៈ ទីតាំងនេះវាសម្លាប់ចោលតែម្តង គ្មានជីករណ្តៅទេ ដោយយកម៉ារ៉ែកនេះតែម្តង ព្រោះទំនប់ខ្ពស់ជិត ២ម៉ែត្រ វាយដាក់ក្នុងនេះតែម្តង ។

8 អំពីអដ្ឋិធាតុ ៈ បាត់បង់អស់ ដោយសត្វជ្រូក គោ ស៊ីគ្មានសល់ឡើយ ។

8 ចំនួនសាកសពជនរងគ្រោះ ៈ ចង១ខ្សែ១ ពី១០ ទៅ ១២នាក់ ដូច្នេះក្នុង ១រណ្តៅ វាយចោល ៣ខ្សែ អាចមួយកន្លែងប៉ាន់ស្មានថា ១២០នាក់ ទៅ ១៥០នាក់ ។ សរុប ៣ កន្លែងនេះមាន ១៦០នាក់ ។

8 អំពីឯកសារទាក់ទងបញ្ហានេះ

- យើងគ្មានឯកសារទេ ប៉ុន្តែយើងមានសាក្សីច្បាស់លាស់ គាត់រស់នៅក្នុងភូមិនេះតាំង តែពីឆ្នាំ ១៩៧០-៧៥ និងទល់ ១៩៧៩ រហូតសព្វថ្ងៃ ហើយសម័យ **លន់ ណុល** ធ្លាប់ធ្វើឈ្លបឃុំ ខ្មែរក្រហមផង (**សាន់ ឡេង**) ។ <u>បញ្ជាក់</u>ៈ ឯកសារខាងវប្បធម៌ ស្រុក អាចមាន ប៉ុន្តែយើងមិនជួបគេ ។
- យើងបានសម្ភាសន៍សាក្សី **សាន់ ឡេង** ចុងក្រោយ ទុកជាឯកសារគួបផ្សំ និងថត រូបចំណាំផង ។

ក្រោយមកម៉ោង ១៣ៈ០០ ម៉ោង ១ៈ០០ រសៀល យើងមកពិសារបាយនៅផ្សារត្រពាំងក្រលឹង។

នៅម៉ោង ១៤ៈ០០ ក្រុមយើងបានចេញដំណើរឆ្ពោះទៅរកទីតាំងប្រល័យពូជសាសន៍នៅ ឃុំតាំង ស្យា ឋិតនៅខាងស្តាំដៃ ចូលជ្រៅទៅខាងជើង ផ្លូវជាតិលេខ ៤ ចំនួន ១០គីឡូម៉ែត្រ ។

<u>ទីតាំងកាប់សម្លាប់</u>

***ភ្នំគន្ធាក់*** ឋិតនៅក្នុងភូមិត្រាំងតាកន ចំងាយពីភូមិទៅភ្នំក្រលាក់ នៅជើងភ្នំចំនួន ៥០០ម៉ែត្រ ទៅ ៦០០ម៉ែត្រ ធ្វើដំណើរកាត់ព្រៃតាមផ្លូវរទេះ ដោយថ្មើរជើង ។ យើងបានរកឃើញលោកតាឈ្មោះ **ជ័យ រស់** អាយុ ៥៤ឆ្នាំ នាំយើងទៅ ហើយគាត់យល់ព្រមធ្វើសាក្សីផង គាត់រស់នៅសព្វថ្ងៃភូមិត្រាំង តាកន

ឃុំតាំងស្យា ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ។ ជនាន់ **ប៉ុល ពត** ដាប់គុក ខ្មែរក្រហម ។ ឆ្នាំ ១៩៧៩ មកស្រុកកំណើតវិញ ។

**អំពីពតិមាន**

លោកតា **ថ័យ រស** បានប្រាប់យើងថា គាត់បានដឹងទីតាំងភ្នំក្រលាក់នេះ គេយកជនរងគ្រោះមកសម្លាប់នៅឆ្នាំ ១៩៧៥-៧៦ គាត់បានឃើញផ្ទាល់ភ្នែកនៅឆ្នាំ ១៩៧៩ ពួកឃាតករវាយសម្លាប់ រួចញាត់ចូលក្នុងឡផ្សង ទំហំមាត់លើ ៤ម៉ែត្រ ជំរៅ ១,៥០ម៉ែត្រ សាកសពពី ២០ ទៅ ៣០នាក់ រណ្តៅឡផ្សងសម្លាប់ពីរ អាចស្មានថាពី ៥០នាក់ ទៅ ៦០នាក់។ អ្នកស្លាប់ទីនេះប្រភេទកម្មាភិបាល និងប្រជាជនខុសសីលធម៌ផ្សេងៗ ។

\+ **ទីតាំងសម្លាប់ជើងភ្នំឈ្មោះ ខាងលិចភ្នំ**

ចំងាយ ១០០ម៉ែត្រ ឆៀងខាងត្បូង វត្តគីរីបឹងជុំ

ទីតាំងសម្លាប់នេះឋិតក្នុងភូមិត្រាំងតាកនដដែល ចំងាយ ១,០០០ ម៉ែត្រ ពីភូមិនៅខាងត្បូងឆៀងខាងលិច ធ្វើដំណើរតាមវត្តគីរីបឹងជុំ ។ ទីនេះវាយសម្លាប់ដាក់ញាត់ចូលឡដុតធ្យូងដូចគ្នា ប៉ុន្តែសម្លាប់ ប្រហែល ១០ ទៅ ១២នាក់ ទេ ។

អំពីអដ្ឋិធាតុ

នៅទីនេះគ្មានរើសអដ្ឋិធាតុតំកល់ទុកទេ តំបន់នេះពួកខ្មែរក្រហមកាន់កាប់ក្រោយឆ្នាំ ១៩៧៩ សន្តិសុខមិនធានាឡើយ រយៈ ១៩៧៩-៨០ រហូត ១៩៨៥ ។

ប្រភេទជនរងគ្រោះស្លាប់ទីនេះ

- ជាពួកកម្មាភិបាលខ្មែរក្រហម ឬ ប្រជាជនខុសសីលធម៌ផ្សេងៗ យកមកពីឆ្ងាយៗ សម្លាប់ ទីនេះ ។
- ឯកសារគ្មាន ប៉ុន្តែយើងសំអាងលើសាក្សី **ថ័យ រស** ដឹងឮ ឃើញផ្ទាល់ ។

យើងបានថតរូបគាត់ និងថតសម្លេងចូលក្នុងកាសែត នូវរបាយការណ៍លំអិតរួច ហើយទុកជាឯកសារគួបផ្សំ ។

**សេចក្តីសន្និដ្ឋាន**

ស្រុកភ្នំស្រួច យើងចុះលើកទី១ និងលើកទី២ ថ្ងៃទី៨ ខែមិថុនា ឆ្នាំ១៩៩៨ នេះមួយលើកទៀត យើងវាយតំលៃ ដូចតទៅ :

ការងាយស្រួល

- ទំនាក់ទំនងអាជ្ញាធរដែនដីថ្នាក់លើខេត្ត ស្រុក បានល្អប្រសើរ និងប៉ូលិស ខេត្ត-ស្រុក ។

*អំពីលទ្ធផលការងារ*

យើងចុះទៅទីតាំងបានតែ ៥កន្លែង នៅទីតាំងឃុំបានតែ ២ គឺ ឃុំអូរ និងឃុំតាំងស្យា ។ ទីតាំងសម្លាប់ដាក់ស្ដែង មានសាក្សីច្បាស់លាស់ ។ ប៉ុន្តែយើងបានសំរេចតិច មូលហេតុ :

- ពេលវេលា កន្លះថ្ងៃ ថ្ងៃទី១
- សន្តិសុខ មិនអំណោយផល
- មន្ត្រីមូលដ្ឋាន សំខាន់ៗ មិនបានជួបគឺ វប្បធម៌ស្រុក អ្នកមានឯកសារ ។

*ទីតាំងធំៗជាទិសដៅខាងមុខគឺ*

- ឃុំដំបូកខ្ពស់
- ឃុំព្រៃក្មេង
- ។ល។

ក- ដុតអិល - តុងឡុង ។ល។
ខ- ក្រាំងរមាស
គ- ទួលដា

*ទីតាំងនេះតាមពត៌មាន*

គឺសម្លាប់ធំបំផុត ច្រើនបំផុត ពីព្រោះតំបន់នេះពួកមេខ្មែរក្រហមធំៗស្ថិតនៅទីនោះ ក្នុងសម័យ **ប៉ុល ពត** ។ នេះជាពន្លឺដ៏សំខាន់របស់យើងតទៅមុខ ។

ឯមធ្យោបាយប្រើពេលវេលា និងកម្លាំងការពារជាមុន ។ កម្លាំងការពារច្រើនប្រើពេល១យប់ ១ថ្ងៃ ។

## II- ស្រុកឧដុង្គ

នៅថ្ងៃទី ៩ ខែ មិថុនា ក្រុមស្រាវជ្រាវយើងបានចុះទៅស្រាវជ្រាវដែនទីសាកសព និងស្វែងរករណ្ដៅកាប់សម្លាប់ សាក្សី ឯកសារ ទាក់ទងអំពើប្រល័យពូជសាសន៍នៅស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ។

+ **<u>លក្ខណៈភូមិសាស្ត្រស្រុក</u>**

យើងបានជួបលោក **សុខ សុផុន** ចៅហ្វាយស្រុក នៅម៉ោង ១៨:០០ ។ យើងបានស្រង់ពត៌មាន ពីគាត់ដូចតទៅនេះ :

ស្រុកខ្សុក្គ មានទីតាំងជាប់ផ្លូវជាតិលេខ ២៣ បាត់ដឹងចំងាយពីសាលាខេត្តកំពង់ស្ពឺ ៣៧ គីឡូម៉ែត្រ ។ ពីផ្លូវជាតិលេខ ៤ ចំនួន ២២គីឡូម៉ែត្រ ។ ពីផ្លូវជាតិលេខ ៥ ចំនួន ៦គីឡូម៉ែត្រ។ ឋិតនៅ តំបន់ ១៥ សម័យប៉ុល-ពត ភូមិ ភាគនិរតី ។

+ **ព្រំប្រទល់ស្រុក**

8 ខាងលិច ទល់ស្រុកថ្ពង ខេត្តកំពង់ស្ពឺ

8 ខាងកើត ស្រុកអង្គស្នួល និងស្រុកពញាឮ ខេត្តកណ្តាល

8 ខាងជើង ស្រុកសាមគ្គីមានជ័យ និងស្រុកកំពង់ត្រឡាច

8 ខាងត្បូង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ។

+ **អំពីមុខរបររកស៊ីប្រជារាស្ត្រ**

8 ធ្វើស្រែ ឡើងត្នោត មាន ១៥ឃុំ និង ២៥១ ភូមិ

8 ចំនួនប្រជារាស្ត្រ ៩៧៣ ០០០ នាក់ ។ (ក្នុងឆ្នាំ ១៩៩៨ នេះ) ។

+ **ទីតាំងប្រល័យពូជសាសន៍ ( កាប់សម្លាប់ )**

8 ភូមិប៊ឹងវ៉ា នៅឃុំត្រាចទង

8 បុស្សីចាស់ ១គុម្ព នៅត្រាចទង

8 ព្រៃប្រមាត់ដី នៅឃុំត្រាចទង

8 ព្រៃក្តាមពង ឋិតនៅឃុំចន្ទ័សែន

+ **ដំណើរឆ្ពោះទៅកាន់ទីតាំងកាប់សម្លាប់**

យើងចេញដំណើរតាមផ្លូវជាតិលេខ ៤១ ចេញពីសាលាស្រុកខ្សុក្គ ទៅសាលាឃុំចន្ទ័សែន យើងបានជួបមេឃុំឈ្មោះ **ឌួប សាវ៉ាន់** មេឃុំចន្ទ័សែន តែម្តង ។

សាក្សីទី២ : ឈ្មោះ **ម៉ូ មឿន** អាយុ ៥៤ឆ្នាំ ជាប្រជាជននៅភូមិត្រពាំងអន្ទង់ ឃុំចន្ទ័សែន ស្រុកខ្សុក្គ ខេត្តកំពង់ស្ពឺ (បច្ចុប្បន្ន) ។ នៅសម័យ **ប៉ុល ពត** ជាឈ្លបភូមិ នៅភូមិ ឃុំនេះ តែម្តង ។

សាក្សីទាំងពីរនាក់នេះ គាត់បានប្រាប់យើងអោយដឹងថា នៅចំងាយពីសាលាឃុំចន្ទ័សែននេះ ១គីឡូម៉ែត្រ ទិសខាងលិច នៅព្រៃក្តាមពង មានរណ្តៅសាកសពជាច្រើនធំៗ គឺរណ្តៅយន្តហោះ B 52 ទំលាក់ក្នុងសម័យ **លន់ ណុល** ហើយរណ្តៅនេះពួកឃាតករបានចាប់ចងទាហ៊ាន ពីបន្ទាយត្រពាំងត្នោត ខាងលិចភ្នំប្រសិទ្ធិ ។ ប្រភេទជនរងគ្រោះ មានទាហ៊ាន ប្រពន្ធ កូន និងប្រជាជនបែកពីទីក្រុង បញ្ជូនមកទាំងខ្សែៗ តាមផ្លូវលេខ ៤១ នោះ យកមកសម្លាប់ទំលាក់ក្នុងរណ្តៅ B 52 នេះពេញៗ តែម្តង ។

នៅឆ្នាំ ១៩៧៩ សាក្សីបានមកកាន់ព្រៃពង្រក្តាមនេះ ឃើញឆ្អឹងជនរងគ្រោះនៅពេញរណ្តៅ B 52 រណ្តៅធំៗ ៣ ពេញទាំងអស់ និងរណ្តៅផ្សេងៗទៀត គាត់មិនបានពិនិត្យ ។ នៅឆ្នាំ ១៩៧៩ ប្រជាជនខ្លះបានទៅជីករកមាស ។ ការប៉ាន់ស្មាន ក្នុងរណ្តៅនីមួយៗ អាចមាន ១៥០នាក់ ទៅ ២០០នាក់ ដូច្នេះ ៣ រណ្តៅធំទាំងបី មានពី ៤៥០នាក់ ទៅ ៦០០នាក់ ។ ទំហំរណ្តៅ មាត់លើ ១០ម៉ែត្រ ទៅ ១២ម៉ែត្រ ។ ជំរៅ ៣ម៉ែត្រ ទៅ ៤ម៉ែត្រ ។ ពួកឃាតករបានសម្លាប់នៅឆ្នាំ ១៩៧៤-៧៥ ឧបករណ៍សម្លាប់គឺ គល់ឫស្សី ត្បូងចប ។

+ **<u>អំពីអដ្ឋិធាតុ</u>**

ឆ្អឹងជនរងគ្រោះកប់នៅក្នុងរណ្តៅ B 52 នេះទាំងអស់ គ្មានយកទៅតំកល់ទុកនៅទីណានោះទេ ។ មូលហេតុ គ្មានឆ្អឹង តំបន់នេះ ឆ្នាំ ១៩៨៥-៨៦-៨៧ នៅប្រទាញប្រទង់ជាមួយពួកខ្មែរក្រហម មិនអាចចូលទៅគាស់ឆ្អឹងបានទេ ។ (ភស្តុតាងបើគាស់អាចឃើញឆ្អឹងជនរងគ្រោះ ) ។

យើងបានទៅពិនិត្យផ្ទាល់រណ្តៅព្រៃពង្រក្តាម រួមជាមួយមេឃុំ សាក្សី បានថតសាក្សី និងរណ្តៅទុកជាឯកសារស្រាប់ ។

យើងបានជួបក្មេងប្រុស ៣ នាក់ ឈ្មោះ :

១- **យា ពៅ** អាយុ ១៦ ឆ្នាំ

២- **ម៉ឹង យឿន** អាយុ ១៦ ឆ្នាំ

៣- **បួង បាន** អាយុ ២០ ឆ្នាំ

ក្មេងនេះរស់នៅភូមិត្រពាំងអន្ទង់ ឃុំចន្ទសែន នេះ ពួកគេបានប្រាប់យើងថា គេបានឃើញឆ្អឹងពេញៗរណ្តៅ B52 នៅទីនោះដែរ ព្រមទាំងបានរើសយកក្បាលជនរងគ្រោះតំកល់ទុកលើដំបូកទៀតផង ព្រោះគេបានមកឃ្វាលគោទីនេះជានិច្ច ។

បញ្ជាក់ : ចំងាយពីទីតាំងសម្លាប់ ព្រៃក្តាមពង ទៅសាលាឃុំ ១គីឡូម៉ែត្រ ពីនេះទៅសាលាស្រុក ឧដុង្គ ១០ គីឡូម៉ែត្រ ។ តាមផ្លូវជាតិលេខ ៤១ បាត់ដឹង ទៅកំពង់ស្ពឺ ។

+ **<u>ទីតាំងប្រល័យពូជសាសន៍</u>**

នៅឃុំត្រពាំងចង មាន :

- ភូមិបឹងវ៉ា ឫស្សីចាស់ ១គុម្ព ព្រៃប្រម៉ាត់ដី
- មន្ទីរសន្តិសុខគុក នៅភូមិស្តុកស្រោត ឃុំមានជ័យ
- មន្ទីរសន្តិសុខ អូថ្កុកអង្រ្គង (កោះនៅទីនោះ) ពួកឃាតករនៅតាមដងអូរនេះ ។

យើងត្រឡប់ក្រោយវិញ ធ្វើដំណើរឆ្ពោះទៅឃុំត្រាចទង ដើម្បីស្វែងយល់ទីតាំងទាំងនេះ នៅ ម៉ោង ១៦:០០ យើងបានជួបមេឃុំត្រាចទង ឈ្មោះ **ផុន រឿន** អាយុ ៥៤ឆ្នាំ ។ យើងបានស្រង់ ពត៌មាន គាត់ថា នៅឫស្សីចាស់ ១គុម្ព ជាទីតាំងសម្លាប់ច្រើនបំផុត រាប់ម៉ឺន និងជាងម៉ឺននាក់ ចំងាយពី សាលាឃុំ ១គីឡូម៉ែត្រ ។ យើងក៏បានរួមដំណើរទៅទីនោះជាមួយមេឃុំ ពិនិត្យជាក់ស្តែង ។ យើងបានសុំឲ្យគាត់ជួយធ្វើជាសាក្សី ព្រោះគាត់ដឹងពិតការកាប់សម្លាប់នេះ យើងក៏បានសម្ភាសន៍គាត់ទុកក្នុងកាសែត ស្រាប់ ។

លោក **ផុន រឿន** ជាសាក្សី បានរាយការណ៍លំអិតប្រាប់យើងថា រណ្តៅនៅទីនេះរាប់ឃើញ ប្រហែលពី ៥០០ ទៅ ១០០០ ពួកវាបានជីកទុកជាមុន ហើយវាបាននាំមកសម្លាប់ក្នុង ១រណ្តៅ ពី ២នាក់ ទៅ ៤នាក់ វាកប់ត្រួតៗលើគ្នា រណ្តៅវាជីកជាជួរៗ គាត់បានឃើញផ្ទាល់នៅឆ្នាំ ១៩៧៥-៧៦ ចំនួនជនរងគ្រោះស្លាប់ ពី ៣,២០០ នាក់ ទៅ ៤,០០០ នាក់ ។

\+ **<u>ប្រភេទជនរងគ្រោះ</u>**

ពួកវាប្រមូលយកមកពីភ្នំពេញ កប់ស្រូវ អន្លង់ក្រង៉ាន ភ្នំប្រសិទ និយាយរួមពីទិសខាងកើត អ្នកជំលៀសចេញពីទីក្រុងនានា ហើយសម្លាប់ចំរុះ ក្មេងចាស់ ប្រុសស្រី និងរួមជាមួយពួកទាហ៊ានខ្មែរក្រហមដែលបាក់ទ័ព ចាញ់ទ័ព រណសិរ្ស ហេង សំរិន រត់មកដល់នោះ ពួកវាឃាត់ចាប់ សម្លាប់ដូចប្រជាជន មន្ត្រីរដ្ឋការដែរ ។

សាក្សីរូបនេះ បានបញ្ជាក់ថា ជនទាន់ **ប៉ុល ពត** គាត់ទៅរស់នៅព្រៃគោល ភូមិទ្រនប់ធំ ឃុំត្រាចទង គាត់ធ្លាប់ចេញចូលព្រៃនេះ ព្រោះគាត់កងភ្ជួរ មកឃ្វាលគោ ក៏ឃើញជាក់ស្តែងតែម្តង នេះការពិត គឺគាត់ឃើញផ្ទាល់ (គាត់ធ្វើមេឃុំតាំងពីឆ្នាំ ១៩៧៩ ) ។

ក្រុមយើងបានសម្ភាសន៍គាត់ទុក នៅព្រៃឫស្សីចាស់មួយគុម្ព នៅម៉ោង ១៧:៣០ យើងបន្តដំណើរមកភ្នំពេញវិញ ។ ចំងាយផ្លូវពីសាលាឃុំចន្ទសែន ទៅឃុំត្រាចទង ៨គីឡូម៉ែត្រ ។ ពីសាលាឃុំត្រាចទង ទៅដល់សាលាស្រុក ១៨គីឡូម៉ែត្រ ។

<u>បញ្ជាក់</u> : ផ្លូវទៅឃុំត្រាចទង បត់ស្តាំ តាមបណ្តោយខ្លោងទ្វារវត្តអង្គព្រលឹង ចូលផុតទំនប់ ទៅដល់វត្ត ១ បត់ស្តាំ ឆ្លងស្ពានថ្ម១ និងទ្វារទឹក ៤ ផុតបន្តិចដល់សាលាឃុំត្រាចទង ។

## សេចក្ដីសន្និដ្ឋាន

ការទំនាក់ទំនងបានល្អ យើងជួបអភិបាលស្រុក និងជួបមេឃុំទាំងពីរឃុំ គឺឃុំចន្ទសែន និងឃុំគ្រាំចទង ។

បញ្ហាសន្តិសុខ

នៅស្រុកខដុន្ត គ្មានចោទជាបញ្ហាសន្តិសុខទេ ដូច្នេះយើងគ្មានប៉ូលិសការពារទេ ទោះបីយើងនៅឆ្ងាយពីសាលាស្រុកក៏បាន ដូច្នេះយើងចប់កិច្ចការនៅម៉ោង ១៧:៣០ម៉ោង នៅព្រៃបុស្សីចាស់ ១គុម្ព ១៨គីឡូម៉ែត្រ ពីសាលាស្រុក ។

**លទ្ធផលការងារ**

នៅទីនេះស្រុកខដុន្ត យើងចុះបានតែ ២ឃុំ និងទីតាំងសម្លាប់ ២ កន្លែង មែនពិត ប៉ុន្តែសំខាន់ គឺទីតាំងព្រៃពងក្ដាម ឃុំចន្ទសែន សម្លាប់ច្រើន ទីតាំងបុស្សីចាស់ ១គុម្ព សម្លាប់រាប់ពាន់ រាប់ម៉ឺន ហើយមានសាក្សី ដឹងឮបានពិតប្រាកដជាក់ស្ដែង ។

**ពត៌មានសំរាប់បន្តទិសដៅទៅមុខ**

មានទីតាំងសម្លាប់ដូចជា ៈ

- ភូមិបឹងវ៉ា ព្រៃប្រម៉ាត់ដី ក្រសាំងផ្អែម
- គុកសន្តិសុខស្ដុកស្រោត
- គុកសន្តិសុខ អូរអន្ទ្រង ដងអូរ (កោះ១) ។ល។

យើងជឿថា មានឃុំខ្លះទៀតអាចមាន ប៉ុន្តែអស់ពេលវេលា ។

យើងសោកស្ដាយ ដោយចុះបានមួយល្ងាច ព្រោះពេលព្រឹកចៅហ្វាយស្រុក មន្ត្រីនានា នគរបាល មេឃុំ ទៅទទួល សម្ដេច **ហ៊ុន សែន** នៅបន្ទាយគ្នាគពងទាំងអស់ ដូច្នេះ ព្រឹកយើងបែរមុខព្រួញចុះទៅវត្តគុក ភ្នំអង្គរស្ស ស្រាវជ្រាវនៅទីនោះវិញ ព្រោះយើងកុំឲ្យខាតពេលវេលា ហើយស្រាវជ្រាវនេះទុកបញ្ចូលរបាយការណ៍នៅស្រុកពញាឮវិញ លទ្ធផលទីតាំងភ្នំអង្គរស្ស ខដុន្តនេះ ។

យើងត្រលប់មកវិញតាមផ្លូវជាតិលេខ ៤១ និងលេខ ៤៣ ឆ្ពោះទៅតាមភ្នំប្រសិទ្ធិ ឡើងព្រែកព្នៅ ដល់ទីក្រុងភ្នំពេញម៉ោង ៧:០០យប់ ។

# III- ស្រុកថ្ពង

នៅថ្ងៃទី ១០ ខែមិថុនា ឆ្នាំ ១៩៩៨ ក្រុមស្រាវជ្រាវយើងបានចុះទៅស្រាវជ្រាវអំពីប្រល័យពូជសាសន៍នៅស្រុកថ្ពង ខេត្តកំពង់ស្ពឺ ។ យើងធ្វើដំណើរពីភ្នំពេញតាមផ្លូវជាតិលេខ៥ បត់ឆ្វេងដៃ រួចធ្វើដំណើរឆ្ពោះទៅទិសលិច ទៅដល់សាលាស្រុកនៅម៉ោង ១០:៤០នាទី ។ ចំងាយផ្លូវពីភ្នំពេញ ដល់ផ្សារឧដុង្គ ៤០គីឡូម៉ែត្រ ។ ទៅដល់ស្រុក ៣៨ គីឡូម៉ែត្រ សរុប ៧៨ គីឡូម៉ែត្រ ។ បើធ្វើដំណើរផ្លូវជាតិលេខ៤វិញ ពីផ្លូវជាតិលេខ៤ បត់ស្តាំដៃ ទៅជើងចំងាយដល់សាលាស្រុក ៣១ គីឡូម៉ែត្រ ។ ពីភ្នំពេញដល់ខេត្តកំពង់ស្ពឺ ៤៨ គីឡូម៉ែត្រ សរុប ៧៩ គីឡូម៉ែត្រ ។

យើងបានទៅដល់សាលាស្រុកនៅម៉ោង ១០:៤០នាទី យើងបានជួបអភិបាលស្រុករង និងអភិបាលស្រុក ឈ្មោះ **មឿខ សែន** និងលោកអនុប្រធានការិយាល័យរដ្ឋបាលស្រុកថ្ពង ។

ក្រុមយើងបានជំរាបអំពីគោលបំណង និង សំណូមពររបស់ក្រុមស្រាវជ្រាវយើងដល់អាជ្ញាធរ ដែនដី និង សុំស្នើអោយគេជួយរួមសហការការងារជាមួយនិងយើង ការពារសន្តិសុខ និង បង្ហាញទីតាំងប្រល័យពូជសាសន៍ដែលមាននៅក្នុងស្រុកថ្ពង ទាំងមូល និងបញ្ហាផ្សេងៗ ។ល។

## អំពីរបាយការណ៍ និងពត៌មាន

**លក្ខណៈភូមិសាស្ត្រ** :

ស្រុកថ្ពងជាតំបន់ព្រៃភ្នំជ្រោះ អូរ ស្ទឹង បឹង តំបន់ខ្ពង់រាប សំបូរព្រៃឈើ ឋិតនៅប៉ែកខាងជើងខេត្តកំពង់ស្ពឺ ។ ហើយស្រុកនេះជាប់ទឹកផុស ស្រុកសាមគ្គីមានជ័យ និងខេត្តកំពង់ឆ្នាំង ។

**ព្រំប្រទល់ស្រុកថ្ពង**

- ខាងលិច ទល់ស្រុកឱរ៉ាល់
- ខាងកើត ស្រុកឧដុង្គ
- ខាងជើង សាមគ្គីមានជ័យ ទឹកផុស ខេត្តកំពង់ឆ្នាំង
- ខាងត្បូង សំរោងទង កំពង់ស្ពឺ

សម័យប៉ុល-ពត ឋិតក្នុងតំបន់ ៣២ ភូមិភាគបស្ចឹម ។ ចំនួនប្រជាជនបច្ចុប្បន្ន ៨១២គ្រួសារ មានចំនួន ៤៣,៥០៣ នាក់ ស្រី ២២,៧៥៨ នាក់ ។ មាន ៧ ឃុំចំណុះស្រុក និង ៧១ភូមិ ។

**អំពីទីតាំងប្រល័យពូជសាសន៍ទូទាំងស្រុក**

តាមរបាយការណ៍ពីលោកអភិបាលស្រុក និងលោកអនុប្រធានការិយាល័យរដ្ឋបាលស្រុក បានឲ្យយើងដឹងថា ទីតាំងប្រល័យពូជសាសន៍មានដូចតទៅ :

- ស្រែតាមឿន ចំងាយពីវត្តកន្សែងសំ ៧០០ម៉ែត្រ

🕮កំពង់ទឹកថ្នល់បំបែក ឃុំអមលាំង

🕮ព្រៃក្បាលខ្មោច ភូមិត្រាញ់វែង ឃុំ ៨មុំ

🕮ភូមិតាកោង

🕮សន្តិសុខគុក ទីឃុំឃាំងសួរចម្លើយ នៅឃុំវាលពង់ ស្រុកថ្ពង ដែរ

**សារៈមន្ទីរ**

គាស់ដាក់ឆ្នាំ ១៩៨៧ ប៉ុន្តែភ្លើងព្រៃរាលឆេះខ្ទេចអស់ហើយ មូលហេតុវត្ត និងព្រៃជាប់គ្នា (វត្តក្នុងព្រៃ) ។

**បញ្ជាក់**

សារៈមន្ទីរទុកអដ្ឋិធាតុនេះនៅក្នុងវត្តកន្សែងសំ ឃុំអមលាំង។ ប្រមូលទុកឆ្នាំ ១៩៨៤ ឆេះឆ្នាំ ១៩៨៦ ។

ការចុះទៅស្រាវជ្រាវដល់ទីតាំងសម្លាប់នៅទីតាំងតាមឿន តាមផ្លូវជាតិលេខ៤៣ ចំងាយពីសាលា ស្រុក ៩ គីឡូម៉ែត្រ ចូលជ្រៅដល់ ។

ក្រុមយើង និងអភិបាលស្រុក ប៉ូលីស រួមដំណើរទៅដល់ទីតាំងស្រែចំការតា **មឿន** ឆ្លងស៊ីងឃុំ អមលាំង ។ ចំងាយ៧០០ម៉ែត្រ ពីផ្លូវជាតិលេខ៤៣ ទីតាំងសម្លាប់នេះ រណ្តៅពួកឃាតករជីកនឹងត្រាក់ទ័រ ឈូសត្រពាំងចាស់ ២(ពីរ) មាត់លើ ១០ម៉ែត្រ ទទឹង ១០ម៉ែត្រ ។ បណ្តោយ ១៦ម៉ែត្រ ជំរៅ ២ម៉ែត្រ ។ ពួកឃាតករដឹក ១២រថយន្ត ក្នុងមួយរថយន្តពី ៦០នាក់ ទៅ ៨០នាក់ ប្រភេទជនរងគ្រោះ ក្មេងជំទង់ៗ កម្លោះ ក្រមុំ នៅលីវ ដឹកយ៉ាងដិតស្អុង ដល់ទីតាំងវត្តកន្សែងសំ អោយចុះម្តងមួយៗ ពួកវាចងដៃរួច ឈរជាជួរ រួចយកខ្សែដោតត្រណោត ហើយបណ្តើរទៅកាន់ទីតាំងសម្លាប់ ។

ចំនួនរណ្តៅធំៗ ២ (ពីរ) វាយរួចឈូសត្រាក់ទ័រកប់វិញ ក្នុងមួយរណ្តៅ យើងប៉ាន់ស្មានជាមួយ សាក្សី **សួន សែម** ប្រហែល ៧២០នាក់ ទៅ ៩៦០នាក់ ។ សរុប ១,៦៨០ នាក់ ។

ប្រភេទជនរងគ្រោះសម្លាប់ទីនោះ យកមកពីព្រលានយន្តហោះ និង កម្មកររោងចក្រទីក្រុង ភ្នំពេញ ។ យើងបានរករណ្តៅ សាក្សីអ្នករួមដំណើរនៅទីតាំងស្រែតាមឿន និងសម្ភាសន៍រួចទុកឯកសារ ។

**ទីតាំងទី ២ ព្រៃក្បាលខ្មោច**

- ទីតាំងនេះឋិតក្នុងភូមិត្រាញ់វែង ចំងាយពីសាលាស្រុក ១គីឡូម៉ែត្រ បត់ឆ្វេងដៃចូលតាមផ្ទះ លោក **សួន សែម** ទៅជ្រៅប្រហែល ៥០០ម៉ែត្រ ដល់ទីតាំងកាប់សម្លាប់ព្រៃក្បាល ខ្មោច ។ យើង

និងសាក្សី បានពិនិត្យឃើញរណ្ដៅជាច្រើនពុំទាន់រលប់នៅឡើយ ឃើញ ក្រណាត់ អាវ-ខោ ដូច្នេះយើងសន្និដ្ឋានថា ជាកម្មករ និងទាហ៊ាន ពីបូព៌ា ។

- ទំហំដីព្រៃក្បាលខ្មោច យើងពិនិត្យរណ្ដៅជាជួរៗ នៅពេញព្រៃកូនឈើ ប្រហែល ៨០ ទៅ ១២០ រណ្ដៅ ព្រៃទទឹង ៥០ម៉ែត្រ បណ្ដោយ ១២០ម៉ែត្រ កប់ពេញក្នុងមួយរណ្ដៅ ពី ៤នាក់ ទៅ ៦នាក់ ។ ដូច្នេះសរុបពី ២៨០នាក់ ទៅ ៤៨០នាក់ និងពី ៤៨០នាក់ ទៅ ៧២០នាក់ ។
- ប្រភេទជនរងគ្រោះនៅទីនេះ កម្មកររោងចក្រនៅស្រុកថ្ពង់នេះ រោងចក្រកាត់ដេរ ៦ រោងចក្រ ក្រឡឹង ១ (ធំៗ) នៅសព្វថ្ងៃ ខោអាវទឹកប៊ិច អាចថាទព័បូព៌ា ទព័បាក់រត់ពីបូព៌ា ពីព្រោះឃើញ ខោអាវទ័ព ។
- ពួកឃាតករសម្លាប់ឆ្នាំ ១៩៧៨ ដើមឆ្នាំ ១៩៧៩ សម្លាប់ក្រោយគេ (ពីព្រោះស្រុកថ្ពង់ ខែ ១-២ និង ខែ ៣ ឆ្នាំ ១៩៧៩ ៣ ខែទើបរំដោះបាន ដូច្នេះវាសម្លាប់ចុងក្រោយគេ ។

ពត៌មានខាងលើ ដឹងដោយសាក្សី **សួន សែម** បច្ចុប្បន្ននេះនៅភូមិក្រាញ់វែង ឃុំ ៨មុំ ស្រុកថ្ពង់ មានតួនាទីជាអនុប្រធានការិយាល័យរដ្ឋបាលស្រុកថ្ពង់ ។ សម័យ **ប៉ុល ពត** រស់នៅភូមិ .................... ឃុំអមលាំង ស្រុកថ្ពង់ ខេត្តកំពង់ស្ពឺ ។

យើងបានថតរូបសំភាសន៍សាក្សីហើយ ប៉ុន្តែឯកសារយើងខ្វះខាត ដោយសារថា ការស្រាវជ្រាវយើងជិត ២០ឆ្នាំ មូលដ្ឋានមិនអាចទុកបាន ។ ឯជនដៃដល់ យើងរកមិនឃើញ ។ (យើងចប់ការងារម៉ោង ១៣:៣០នាទី រសៀល យើងមកហូបបាយនៅផ្សារថ្ពង់ជាមួយអភិបាលស្រុក និងសហការីរួមដំណើរ ៦នាក់ ។ ពិសារបាយរួច ម៉ោង ១៤:០០ ។

## សេចក្តីសន្និដ្ឋាន

### ការងាយស្រួល

យើងងាយស្រួលដោយសារលោកអភិបាលស្រុក អនុប្រធានសាលាស្រុក ប៉ូលីស រួមដំណើរ និងក្តាប់បានច្បាស់ទីតាំងប្រល័យពូជសាសន៍ទូទាំងស្រុក ។

### ការលំបាក

យើងជួបការលំបាក ដោយសារផ្លូវទៅកាន់ស្រុកពីផ្លូវជាតិលេខ ៤ ចុះមកស្រុកលំបាកណាស់ នាំអោយយើងយឺតដំណើរ ។

**<u>បញ្ហាសន្តិសុខ</u>**

នៅតាមដងផ្លូវ មានអ្នកយាមហូរហែរដែរ ដូច្នេះសន្តិសុខនាពេលនេះ គ្មានអ្វីចោទឡើយ ប៉ុន្តែទៅឆ្ងាយៗ ត្រពាំងជោ ទិវ៉ាល់ មានបញ្ហាមិនអាចទៅបាន ដោយគ្មានកំលាំងការពារបានទេ ។

**<u>អំពីលទ្ធផលរបស់ក្រុមយើង</u>**

យើងបានចុះតែ ២កន្លែងក៏មែនពិត គឺ ៖

១- ស្រែតា **មឿន** ជាទីតាំងធំ

២- ព្រៃក្បាលខ្មោច នៅទីតាំងសម្លាប់ច្រើន

ប៉ុន្តែចំណុចសំខាន់ យើងមានពន្លឺទៅពេលមុខទៀត បើមានកម្មវិធី យើងដឹងទីតាំងស្រាប់ហើយ ទីតាំងយើងចុះមិនបានគឺ ៖

- ◊ កំពង់ទឹកថ្មល់បំបែក ទីតាំងនេះចំងាយ ១២ គីឡូម៉ែត្រ ចូលជ្រៅ ៧០០ម៉ែត្រ ឆ្លងអូរផុត ចូលដីស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង (បញ្ហាសន្តិសុខ) ។
- ◊ ខាងជើងភូមិតាកោង ១១គីឡូម៉ែត្រ ដល់ឃុំអមឡាំង ទៅពីឃុំ ៣ គីឡូម៉ែត្រ (អស្ដេរ ភាព) ។
- ◊ ត្រពាំងអង្រ្គង ១៤ គីឡូម៉ែត្រ ពីសាលាស្រុកចូលដី ស្រុកទឹកផុស (គ្មានសន្តិសុខ) ។

# IV- <u>ស្រុកសំរោងទង</u>

ស្រុកសំរោងទង ឋិតតាមដងផ្លូវជាតិលេខ ៤ ខាងកើតទិរួមខេត្តកំពង់ស្ពឺ ស្រុកនេះឆ្នាំ ១៩៩៧ យើងបានចុះទៅជួបលោកចៅហ្វាយស្រុក និងវប្បធម៌ស្រុកម្តងរួចហើយ ចៅហ្វាយស្រុករាយការណ៍ឲ្យយើងដឹងថា គ្មានទីតាំងកាប់សម្លាប់ទេស្រុកនេះ ។

យើងប៉ាន់ស្មានវាយតម្លៃថា ស្រុកនេះនៅតាមដងផ្លូវ ហើយនៅកណ្តាល ជិតទីក្រុង ជិតផ្លូវជាតិ ពួកប៉ុលពត មិនទុកប្រជាជននៅក្បែរៗនេះទេ វាអាចយកទៅឆ្ងាយៗ ជ្រៅៗ មែនហើយ ។

**<u>សេចក្តីសន្និដ្ឋានរួមទូទាំងខេត្ត ៣ស្រុក</u>**

ចុះរួចនាឆ្នាំ ១៩៩៨ នេះ

កម្មវិធីដាក់អោយចុះ១ថ្ងៃ ទៅស្រុកមួយមិនសមស្របឡើយ ពីព្រោះស្រុកនីមួយៗមាន ១២ឃុំ ៧ឃុំ និង ១៥ឃុំ រាប់រយភូមិ ផ្លូវឆ្ងាយ សន្តិសុខ ដូច្នេះត្រូវស្មាបស្ទង់ច្បាស់លាស់ ទើបអាចចុះទៅបាន នេះហើយដែលយើងត្រូវតែប្រើពេលវេលា ។

បញ្ហាម្យ៉ាងទៀត ផ្លូវឆ្ងាយៗ លំបាកពីខេត្តទៅស្រុក ពីស្រុកទៅឃុំ - ភូមិ ទៅទីតាំង ជួនកាលចុះដើរថ្មើរជើង នេះវាខ្វីណាស់ ។ (ពិចារណា)

ម្យ៉ាងទៀតមន្ត្រីសំខាន់ ដូចជាវប្បធម៌ស្រុក គេចូលក្នុងគណៈកម្មការរៀបចំបោះឆ្នោតអស់ ដូច្នេះយើងខ្វះពត៌មាន ខ្វះឯកសារជំនួយ និងគួបផ្សំ ហើយ ។

ប៉ុន្តែថ្វីបើពេលវេលាខ្លីមែនពិត យើងក៏បានដឹងពត៌មានបន្ថែមទៅមុខទៀត នូវទីតាំងសំខាន់ៗមួយចំនួនតាមស្រុក ឃុំនីមួយៗផងដែរ ។

ដូច្នេះយើងមានពន្លឺ ប្រយោជន៍ ឲ្យយើងលើកគំរោងកម្មវិធី ទិសដៅបន្តរទៅបណ្តាខែ ឆ្នាំ ខាងមុខបានល្អ ។

ចំពោះបញ្ហាសន្តិសុខ បើយើងរិះរកមធ្យោបាយ វិធានការគ្រោងទុក ប្រើពេលវេលា កម្លាំង ថវិការយើងអាចសំរេចបាន ប៉ុន្តែអាស្រ័យលើការតស៊ូ និងហ៊ានផងដែរ ។

ធ្វើនៅភ្នំពេញ, ថ្ងៃទី ១០ ខែមិថុនា ឆ្នាំ ១៩៩៨

អ្នកធ្វើរបាយការណ៍

**ស៊ិន ឃិន**